# ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជា

ដោយបណ្ឌិត **ឈឿន ម៉ុនឆា**[១]

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាមានមហិច្ឆតាក្នុងការផ្លាស់ប្តូរពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាបទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ ហើយបន្តក្លាយជាប្រទេសអភិវឌ្ឍនូវកំណើនសេដ្ឋកិច្ច និងការប្រកួតប្រជែងនាពេលបច្ចុប្បន្ននិងពេលអនាគតរបស់កម្ពុជា។

កត្តាចម្បងនិងយ៉ាងសំខាន់បំផុតនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គឺការទទួលបាននូវស្ថិរភាពនយោបាយ ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិ។ តួយ៉ាង ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការអភិវឌ្ឍវិស័យឯកជនឱ្យកាន់តែរស់រវើក តាមរយៈការលើកកម្ពស់បរិយាកាសធុរកិច្ចនិងវិនិយោគ ដែលជាប្រភពនៃការបង្កើតការងារក្នុងគ្រប់វិស័យ ព្រមទាំងជាចលករសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចជាតិ។ ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ត្រូវបានប្រទេសកំពុងអភិវឌ្ឍបាននឹងកំពុងបង្កើត និងអភិវឌ្ឍនូវតំបន់នេះយ៉ាងច្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

## ២. ពាក្យថាតំបន់សេដ្ឋកិច្ចពិសេស

### ២.១. អ្វីទៅហៅថា "តំបន់សេដ្ឋកិច្ចពិសេស"?

**"តំបន់សេដ្ឋកិច្ចពិសេស"** (Special Economic Zone/SEZ) សំដៅលើតំបន់ទាំងឡាយណាដែលមានលក្ខខ័ណ្ឌវិនិយោគដាច់ដោយឡែកពីបទប្បញ្ញត្តិ ឬច្បាប់របស់រដ្ឋត្រូវបានអនុវត្តនៅតំបន់ទូទៅ[២]។ លក្ខណៈដោយឡែកនេះហើយ ដែលគេឱ្យឈ្មោះថា "**ពិសេស**"។ ជាធម្មតា បទប្បញ្ញត្តិនៅក្នុងវិស័យវិនិយោគនៅតំបន់សេដ្ឋកិច្ចពិសេស ច្រើនតែដាក់ឱ្យអនុវត្តចំពោះវិនិយោគិនបរទេសដែលបណ្តាក់ទុននៅក្នុងប្រទេសណាមួយ។ ការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសបង្កលក្ខណៈងាយស្រួលសម្រាប់អ្នកវិនិយោគ ដើម្បីទទួលបានការអនុគ្រោះពន្ធអាករ និងការបង់ពន្ធនាំចេញឬនាំចូលទាបជាងកម្រិតទូទៅ[៣]។ ភាគច្រើនតំបន់សេដ្ឋកិច្ចពិសេសត្រូវបានបង្កើតឡើងដើម្បីទាក់ទាញអ្នកវិនិយោគបរទេសទៅបណ្តាក់ទុននៅក្នុងប្រទេសដែលបង្កើតតំបន់នេះ។

---

[១] មន្ត្រីជំនួយការបណ្ឌិតសភាចារ្យ លេខាធិការដ្ឋានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា និងជាលេខាធិការមជ្ឈមណ្ឌលស្រាវជ្រាវអាស៊ីនៃរាជបណ្ឌិត្យសភាកម្ពុជា។

[២] "តំបន់សេដ្ឋកិច្ចពិសេស និងការទាញយកតម្លៃពីតំបន់មេគង្គ" ករណីសិក្សាឆ្នាំ២០១៧។

[៣] "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រដ្ឋាភិបាលកម្ពុជា" ឆ្នាំ២០១៤-២០១៨។

តំបន់សេដ្ឋកិច្ចពិសេស គឺជាឧបករណ៍សេដ្ឋកិច្ចដ៏សំខាន់ដែលត្រូវបានអនុវត្តដើម្បីទទួលបានលទ្ធផលផ្សេងៗគ្នាដោយប្រើប្រាស់នូវមធ្យោបាយក៏ផ្សេងៗគ្នាផងដែរ។ ជាមួយគ្នានេះ ក្របខណ្ឌច្បាប់និងអភិបាលកិច្ចរបស់តំបន់សេដ្ឋកិច្ចពិសេសនីមួយៗត្រូវបានកែសម្រួល ដើម្បីឱ្យមានភាពប្រជំប្រសងគ្នារវាងផលប្រយោជន៍អ្នកវិនិយោគ និងប្រជាជនមូលដ្ឋានប្រកបដោយនិរន្តរភាព។ ជាក់ស្តែង ការបង្កើតនិងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសនៅរាជធានីភ្នំពេញ និងខេត្តព្រះសីហនុដែលជាតំបន់សេដ្ឋកិច្ចជាប់មាត់សមុទ្រមួយដ៏សំខាន់ក្នុងភាគនិរតីនៃប្រទេសកម្ពុជា។

### ២.២. វត្ថុបំណងនៃការបង្កើតតំបន់សេដ្ឋកិច្ចពិសេស

នៅក្នុងចំណោមប្រទេសទាំងអស់នៅលើសកលលោក ដែលយកគោលនយោបាយ "**តំបន់សេដ្ឋកិច្ចពិសេស**" ទៅអនុវត្តទទួលបានជោគជ័យខ្លាំងជាងគេគឺប្រទេសចិន។ លក្ខណៈពិសេសរបស់ប្រទេសចិននៅត្រង់ថា រដ្ឋាភិបាលបានកំណត់យកខេត្តមួយឈ្មោះ ហាយណាន (Hainan) ដែលមានផ្ទៃក្រឡា ៣៣ ២១០ គីឡូម៉ែត្រការ៉េធ្វើជាតំបន់សេដ្ឋកិច្ចពិសេសទាំងមូល[៤]។ ដោយឡែក ប្រទេសដទៃក៏ចាប់ផ្តើមបង្កើតតំបន់សេដ្ឋកិច្ចពិសេសត្រឹមតែតំបន់ទីប្រជុំជន ឬតំបន់ក្រវាត់ទីក្រុងតែប៉ុណ្ណោះ។ ប៉ុន្តែសាធារណរដ្ឋប្រជាមានិតចិនបានយកខេត្តមួយទាំងមូលធ្វើជាតំបន់សេដ្ឋកិច្ចពិសេសតែម្តង។

វត្ថុបំណងសំខាន់នៃការបង្កើតតំបន់សេដ្ឋកិច្ចពិសេសដើម្បីទាក់ទាញអ្នកវិនិយោគពី ក្រៅស្រុកឱ្យទៅវិនិយោគនៅក្នុងប្រទេសណាមួយ។ ព្រោះការវិនិយោគផ្ទាល់ពីក្រៅប្រទេស (Foreign Direct Investment/FDI) មានសារៈប្រយោជន៍សម្រាប់ស្រូបទាញទុនបន្ថែមលើ វិនិយោគិននៅក្នុងស្រុកដែលមានស្រាប់។ វត្ថុបំណងសំខាន់មួយទៀត គឺដើម្បីបង្កលក្ខណៈល្អប្រសើរដើម្បីប្រទេសមួយប្រកួតប្រជែងខាងទំនិញ/សេវាកម្ម និងតម្លៃទល់នឹងប្រទេសដទៃនៅលើទីផ្សារក្នុងតំបន់និងទីផ្សារអន្តរជាតិ ជាពិសេសផ្តោតលើការនាំចេញ។

## ៣. ប្រវត្តិនៃការកកើតតំបន់សេដ្ឋកិច្ចពិសេស

"តំបន់សេដ្ឋកិច្ចពិសេស (Special Economic Zone)" សំដៅលើតំបន់ទាំងឡាយណាដែលមានលក្ខខ័ណ្ឌវិនិយោគដាច់ដោយឡែកពី បទបញ្ញត្តិ ឬច្បាប់របស់រដ្ឋដែលអនុវត្តនៅតំបន់ទូទៅ។ លក្ខណៈដោយឡែកនេះហើយដែលគេឱ្យឈ្មោះថា "**ពិសេស**"។

កាលពីអតីតកាល ក៏ទម្រង់សេដ្ឋកិច្ចរបៀបនេះត្រូវបានគេយកទៅអនុវត្តជាបណ្តើរៗរួចជាស្រេច។ ប៉ុន្តែកាលសម័យនោះ គេប្រើពាក្យផ្សេងពីនេះ។ តាំងពីរាប់សតវត្សមុនមកម្ល៉េះ គេប្រើពាក្យ "តំបន់ស្វយ័ត" ឬ"តំបន់ឧស្សាហកម្ម" សំដៅលើតំបន់ដែលមានសិទ្ធិពិសេស អាចស្តុកទុកទំនិញ និងការដោះដូរទំនិញគ្នា

---

[៤] "របាយការណ៍បរិយាកាសវិនិយោគនៅកម្ពុជា" ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០១៥។

ដោយសេរីនិងស្ថិតក្នុងលក្ខខ័ណ្ឌប្រកប[៥]។ ក្រោយមក កាលពីក្នុងអំឡុងទសវត្សទី៥០ បណ្តាប្រទេសដែលរីកលូតលាស់ខាងវិស័យឧស្សាហកម្មបានកំណត់ប្រើពាក្យ "តំបន់សេដ្ឋកិច្ចពិសេស"។ តំបន់សេដ្ឋកិច្ចពិសេសដំបូងគេ ត្រូវបានប្រទេសអៀកឡង់ (Ireland) យកទៅអនុវត្តនៅតំបន់អាកាសយានដ្ឋានសានណុង (Shannon)។ ចាប់ពីទសវត្សទី៧០ បណ្តាប្រទេសនៅអាមេរិកឡាទីន និងនៅអាស៊ីបូព៌ា បានបង្កើតតំបន់សេដ្ឋកិច្ចពិសេស ដែលប្រមូលផ្តុំដោយរោងចក្រ/ឧស្សាហកម្ម និងស្រូបទាញកម្លាំងពលកម្មក្នុងបរិមាណយ៉ាងច្រើន។ ប្រទេសដែលបង្កើតតំបន់សេដ្ឋកិច្ចពិសេសអាចទាក់ទាញអ្នកវិនិយោគទុននៅក្នុងក្រុមហ៊ុនកម្រិតអន្តរជាតិចូលទៅបណ្តាក់ទុន។

តំបន់សេដ្ឋកិច្ចពិសេស គឺមានស្ទើរតែនៅគ្រប់នៃបណ្តាប្រទេសឧស្សាហកម្មជឿនលឿននៅលើពិភពលោក។ ក្នុងនោះ នៅក្នុងសហរដ្ឋអាមេរិកចំនួនតំបន់នេះមានច្រើនជាងគេបំផុតច្រើនជាង៦០០។ តំបន់សេដ្ឋកិច្ចពិសេស ដែលមានចំណាស់ជាងគេនិងធំជាងគេគឺមាននៅទីក្រុងញូវយ៉ក (New York) ហើយគេក៏ត្រូវបានរៀបចំឡើងនៅទីក្រុងបូស្តុន ឈីកាហ្គោ (Chicago) សាន់ហ្វ្រាន់ស៊ីស្កូ (San Francisco) និងនៅទីក្រុងផ្សេងៗទៀត។ នៅក្នុងឆ្នាំ១៩៨២ តម្លៃទំនិញសរុបដែលបានផលិត និងកែច្នៃនៅក្នុងតំបន់សេដ្ឋកិច្ចទាំងអស់នោះ បានកើតឡើងដល់៩៣,៨៣ាន់លានដុល្លារ រីឯនៅចុងឆ្នាំ១៩៩០ មានចំនួនពី១៣០-១៥០ពាន់លានដុល្លារក្នុងមួយឆ្នាំ ហើយរហូតចុងឆ្នាំ២០១៨ មានចំនួនពី ៩៥០-១៥០០ពាន់លានដុល្លារក្នុងមួយឆ្នាំ[៦]។

ភាពល្បីល្បាញធំជាងគេនៃតំបន់សេដ្ឋកិច្ចពិសេស ត្រូវបានទទួលជោគជ័យនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ នៅក្នុងឆ្នាំ១៩៨១ តំបន់សេដ្ឋកិច្ចពិសេសត្រូវបានបង្កើតឡើងដំបូងចំនួន៩៦តំបន់ ហើយប្រមាណដប់ឆ្នាំក្រោយមក ចំនួននេះបានកើនឡើងក្នុងកម្រិតមួយយ៉ាងគំហុករហូតដល់ជាង៣០០តំបន់ ហើយនឹងបន្តកើនឡើងទៀត។ ចំនួនការងារសរុបនៅក្នុងសហគ្រាស ដែលបានចុះបញ្ជីនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសបានកើនឡើង៣០លាននាក់ គិតត្រឹមចុងឆ្នាំ២០១៨។

បច្ចុប្បន្ននេះ តំបន់សេដ្ឋកិច្ចពិសេសដែលមានច្រើនបំផុត គឺស្ថិតនៅតំបន់អាស៊ីអាគ្នេយ៍ និងក្នុងប្រទេសចិន។ ភារកិច្ចសំខាន់របស់តំបន់នេះគឺការទាក់ទាញនូវទុនវិនិយោគបរទេស ការនាំចូលពីបរទេសនូវបច្ចេកទេសនិងបច្ចេកវិទ្យានាំមុខ ការខ្ចីវិធីសាស្ត្រនៃការគ្រប់គ្រងបែបទំនើប ការទទួលបាននូវព័ត៌មានអំពីស្ថានភាពនៅលើទីផ្សារអន្តរជាតិ។ តួនាទីសំខាន់នៃតំបន់ គឺព្យាយាមនៅក្នុងការពង្រីកការនាំចេញ ការបង្កើនចំណូលរូបិយវត្ថុក្នុងប្រទេស ការចូលរួមនៅក្នុងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស

---

[៥] "ច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគរបស់ព្រះរាជាណាចក្រកម្ពុជា" ឆ្នាំ២០០៣ មាត្រា១៦។

[៦] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៤-២០១៨។

អន្តរជាតិ ការបណ្តុះបណ្តាលអ្នកជំនាញនៅក្នុងវិស័យសហប្រតិបត្តិការពាណិជ្ជកម្មនិងសេដ្ឋកិច្ច និងវិស័យវិទ្យាសាស្ត្រនិងបច្ចេកទេសអន្តរជាតិ។

### ៣.១. លក្ខណៈសម្គាល់នៃតំបន់សេដ្ឋកិច្ចពិសេស

តំបន់ដែលត្រូវបានចាត់ទុកជាតំបន់សេដ្ឋកិច្ចពិសេស៖

- តំបន់ពាណិជ្ជកម្មសេរី (Free Trade Zones/FTD)
- តំបន់ផលិតទំនិញសម្រាប់នាំចេញ (Export Processing Zones/EPZ)
- តំបន់សេរីឬតំបន់សេដ្ឋកិច្ចសេរី (Free Zone/Free Economic Zones/FEZ)
- សួនឧស្សាហកម្ម (Industrial Parks/IP)
- តំបន់កំពង់ផែសេរី (Free Ports/FP)
- តំបន់សហគ្រាសទីក្រុង (Urban Enterprise Zones/UEZ)

### ៣.២. ការដែលប្រទេសមួយបង្កើតតំបន់សេដ្ឋកិច្ចពិសេស

ភាពចាំបាច់បង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេសគឺដើម្បី៖

- បង្កលក្ខណៈងាយស្រួលសម្រាប់ដំណើរការផលិតកម្មក្នុងវិស័យឧស្សាហកម្ម សំដៅលើកស្ទួយសេដ្ឋកិច្ចជាតិ។
- លើកកម្ពស់ ឬបញ្ជ្រាបគំនិតគាំទ្រការនាំផលិតផល និងសេវាកម្មទៅលក់នៅក្រៅប្រទេស។
- លើកកម្ពស់ឬបញ្ជ្រាបគំនិតគាំទ្រការផ្សព្វផ្សាយការវិនិយោគ (ទាំងការវិនិយោគពីវិនិយោគិនជាតិ និងទាំងវិនិយោគិនពីស្រុកក្រៅមកបណ្តាក់ទុននៅប្រទេស)។
- បង្កលក្ខណៈងាយស្រួលសម្រាប់ប្រជាពលរដ្ឋមានការងារធ្វើ។
- អភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធ និងវិស័យដទៃទៀត ដើម្បីបង្កលក្ខណៈងាយស្រួលសម្រាប់ការបណ្តាក់ទុន។

## ៤. អត្ថប្រយោជន៍នៃការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស

ការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសផ្តល់អត្ថប្រយោជន៍ដូចជា៖

- អ្នកវិនិយោគទទួលបានការអនុគ្រោះពន្ធគយនិងពន្ធអាករ។
- ទទួលបានការលើកលែងពន្ធលើប្រាក់ចំណេញ។
- ទទួលបានការលើកលែងពន្ធអប្បបរមា។
- ទទួលបានការលើកលែងពន្ធលើភាគលាភចំពោះសហគ្រាសសហកម្មសិទ្ធិ។
- ទទួលបានការលើកលែងពន្ធលើការលក់ទំនិញនិងសេវា។
- ទទួលបានបរិយាកាសវិនិយោគប្រកបដោយសក្តានុពល។
- ទទួលបានការការពារដោយច្បាប់រដ្ឋ។

## ៥. សន្និដ្ឋាន

តំបន់សេដ្ឋកិច្ចពិសេស ជាតំបន់ដែលមានការវិនិយោគនៃបណ្ដាក្រុមហ៊ុនសហគ្រាសនានានៅក្នុងប្រទេសកម្ពុជា ដែលភាគច្រើនសំបូរដោយវិនិយោគិនបរទេសមកបណ្ដាក់ទុននៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។ លើសពីនេះ តំបន់សេដ្ឋកិច្ចពិសេសក៏បានផ្ដល់ការងារជូនដល់កម្មករ-កម្មការិនីកម្ពុជារាប់សិបម៉ឺននាក់ ដោយទទួលបានប្រាក់ចំណូលតាមស្តង់ដារាជរដ្ឋាភិបាលសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ ប្រជាពលករម្នាក់ៗទទួលបានប្រាក់បៀវត្សទៅតាមស្តង់ដារបស់រាជរដ្ឋាភិបាលកម្ពុជា ដោយសារតែក្រុមហ៊ុនដែលវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ភាគច្រើនជាក្រុមហ៊ុនបរទេស។ តំបន់ឧស្សាហកម្មដ៏ទូលំទូលាយទាំងនេះបានផ្ដល់ការលើកទឹកចិត្ត អនុគ្រោះទៅកាន់វិនិយោគិន និងការគាំទ្រផ្នែករដ្ឋបាលសម្រាប់ការនាំចេញ-នាំចូល ដើម្បីសម្របសម្រួលដល់ការធ្វើពាណិជ្ជកម្ម។ ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសនាំឱ្យមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធយ៉ាងគួរឱ្យកត់សម្គាល់ជាច្រើន ហើយតំបន់ទាំងនេះត្រូវបានបង្កើតឡើងដើម្បីទាក់ទាញវិនិយោគទុនបរទេស ពង្រីកការប្រកួតប្រជែងជាសកល និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។

ដូចនេះ រាជរដ្ឋាភិបាលបានលើកស្ទួយតំបន់សេដ្ឋកិច្ចពិសេស ដើម្បីអនុវត្តនូវគោលការណ៍ និងលក្ខខណ្ឌដែលធានាបាននូវតម្លាភាព ប្រសិទ្ធភាព និងប្រតិបត្តិការរហ័ស គណនេយ្យភាពចំពោះអ្នកវិនិយោគ ការទទួលបាននូវតម្រូវការអំពីព័ត៌មាន និងភាពស៊ីចង្វាក់គ្នាទៅជាមួយនឹងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការបង្កើត និងអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស។

## ឯកសារយោង


១) អនុក្រត្យ លេខ១៤៨ មាត្រា១ ២ ៣ ស្តីពី *"ការបើកគ្រឹះស្ថាន និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស"* ឆ្នាំ២០១០។

២) អនុក្រឹត្យ លេខ១៤៧ អនក្រ.បក ស្តីពី *"ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ"* ឆ្នាំ២០០៥។

៣) របាយការណ៍ដោយៈ CamMcGrath *"តំបន់សេដ្ឋកិច្ចពិសេសដែលធំជាងគេនៅកម្ពុជានឹងមានទំហំកាន់តែធំជាងមុន"* ឆ្នាំ២០១៧។

៤) Peter Warr និង Jayant Menon *"តំបន់សេដ្ឋកិច្ចពិសេសប្រទេសកម្ពុជា"* ឆ្នាំ២០១៥។

៥) Peter W.; and Jayant M. (2015), Cambodia's Special Economic Zones, ADB Economic Working Series, No 459.

៦) http://sezindia.nic.in/HTMLS/SEZ%20Act,%202005.pdf

៧) http://www.chinaeconomicreview.com/industrial-zones/category/special-economic-zone